**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# លិខិតជូនពរ

**សូមគោរពជូន**
**ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី**
**និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ក្នុងឱកាសដ៏មហាប្រសើរប្រកបដោយក្តីសោមនស្សរីករាយ នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវអំណរសាទរយ៉ាងក្លៀវក្លាក្រៃលែង និងការគោរពកោតសរសើរ ជូនចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ដែលបាននិងកំពុងពុះពារ លះបង់នូវកម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី ដើម្បីបុព្វហេតុជាតិមាតុភូមិ រួមចំណែកយ៉ាងសំខាន់ដល់ការរីកចម្រើនយ៉ាងឆាប់រហ័សនិងច្រើនឥតគណនាលើគ្រប់វិស័យទាំងអស់នៅកម្ពុជា និងសេចក្តីសុខក្សេមក្សាន្តរបស់ប្រជាជនដូចសព្វថ្ងៃ។

ក្នុងឱកាសប្រកបដោយសិរីសួស្តី នៃអំណរសាទរឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ ព្រមទាំងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក ពិសេសទេវតាឆ្នាំថ្មី ព្រះនាម **កិមិរាទេវី** សូមយាងប្រោសប្រទានពរជ័យ បវរសួស្តី សិរីមង្គលគ្រប់ប្រការជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងលោកជំទាវ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបុព្វហេតុជាតិ រួមចំណែកកសាងនិងអភិវឌ្ឍជាតិកម្ពុជា ឱ្យកាន់តែឈានឆ្ពោះទៅការរីកចម្រើនបន្ថែមទៀត ពិសេសធានាបាននូវស្ថិរភាពនៃសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ភាពសម្បូរុងរឿង និងសុភមង្គលរបស់ប្រជាជនកម្ពុជាជានិច្ចនិរន្តរ៍តរៀងទៅ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងលោកជំទាវ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សមប្រកបនឹងព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃ ចន្ទ ៥ រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh